# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ:** ០០៧ គ.ជ.ប.ស.ព.ន

# សេចក្តីអំពាវនាវ
## ចំពោះប្រជាពលរដ្ឋខ្មែរដែលកំពុងបំពេញបេសកកម្ម ធ្វើការ ឬសិក្សានៅក្រៅប្រទេស

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (**គ.ជ.ប**) មានកិត្តិយសសូមអំពាវនាវចំពោះប្រជាពលរដ្ឋខ្មែរដែលកំពុងបំពេញបេសកកម្ម ធ្វើការ ឬសិក្សានៅក្រៅប្រទេសទាំងអស់ឱ្យបានជ្រាបថា ៖

១. ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១ ចាប់ផ្តើមពីថ្ងៃទី១២ ខែតុលា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ នៅតាមសាលាឃុំ សង្កាត់ ឬនៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ ទូទាំងប្រទេសកម្ពុជា ដែលបើកធ្វើការជារៀងរាល់ថ្ងៃ ( **ក្នុងម៉ោងធ្វើការ** ) គិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ។

២. បងប្អូនប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិបោះឆ្នោត ហើយមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក ឬអ្នកទើបគ្រប់អាយុ ១៨ឆ្នាំ **គឺអ្នកដែលកើតមុន ឬត្រឹមថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៤** ដែលកំពុងបំពេញបេសកកម្ម ធ្វើការ ឬសិក្សានៅក្រៅប្រទេស សូមអញ្ជើញមកជួបក្រុមចុះឈ្មោះបោះឆ្នោត នៃឃុំ សង្កាត់របស់ខ្លួន ដើម្បីចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១ ឱ្យបានទាន់ពេលវេលាតាមកាលបរិច្ឆេទដែលបានកំណត់កុំបីខាន។

៣. ការមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០២១ ពិតជាមានសារៈសំខាន់ណាស់ ដើម្បីអាចឱ្យសាមីខ្លួនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។

**សូមបញ្ជាក់ថា ៖ បើបងប្អូនគ្មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០២១ នោះ បងប្អូននឹងពុំអាចបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ បានទេ។**

អាស្រ័យហេតុនេះ **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** សូមអំពាវនាវដល់ស្ថានឯកអគ្គរាជទូត និងស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនានា មេត្តាជួយផ្សព្វផ្សាយសេចក្តីអំពាវនាវនេះ ដល់ប្រជាពលរដ្ឋខ្មែរ ដែលកំពុងបំពេញបេសកកម្ម ធ្វើការ ឬសិក្សានៅក្រៅប្រទេសឱ្យទទួលបាននូវព័ត៌មាននេះ ដើម្បីបងប្អូនប្រជាពលរដ្ឋខ្មែរអញ្ជើញមកចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់ៗគ្នា។

ថ្ងៃអង្គារ ៨កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០២១

**ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**